**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទក្រសួង និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា មានអ្នកជម្ងឺនៅគ្រប់មន្ទីរពេទ្យទាំងអស់ក្នុងរាជធានីភ្នំពេញ ត្រូវការឈាមប្រមាណ១៥០ប្លោក ជារៀងរាល់ថ្ងៃ ដើម្បីព្យាបាល និងជួយសង្គ្រោះជីវិតជាបន្ទាន់ ក្នុងនោះមានអ្នកជំងឺមួយចំនួនបានបញ្ជូនមកពីខេត្តនានាទូទាំងប្រទេសផងដែរ ដូចនេះ មជ្ឈមណ្ឌលជាតិផ្តល់ឈាម នៃក្រសួងសុខាភិបាល បានស្នើសុំសហការជាមួយក្រសួង ដើម្បីធ្វើការអប់រំផ្សព្វផ្សាយ និងទទួលអំណោយឈាមដោយស្ម័គ្រចិត្ត សម្រាប់ជួយដល់ជនរងគ្រោះ និងអ្នកជំងឺ ក្រសួងសូមស្នើសុំ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទក្រសួង និងមន្ត្រីរាជការទាំងអស់ មេត្តាផ្តល់ឈ្មោះ និងចំនួនអ្នកចូលរួមបរិច្ចាកឈាមឲ្យបានត្រឹម *ថ្ងៃ សុក្រ ទី២៨ ខែតុលា ឆ្នាំ២០១៦* មកកាន់នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ដើម្បីធ្វើការបូកសរុប និងសម្របសម្រួលការងារជាមួយមជ្ឈមណ្ឌល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទក្រសួង និងមន្ត្រីរាជការទាំងអស់ ចូលរួមសហការតាមការគួរ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦


សូមទំនាក់ទំនងមកទូរស័ព្ទលេខ:

០៧៧ ៨៥២ ៥៦៧

០៩៧ ៤៧៣ ៨៩១៣